# ការចិញ្ចឹមគោជាលក្ខណៈគ្រួសារ

## សេចក្តីផ្តើមៈ

ការចិញ្ចឹមគោជាលក្ខណៈគ្រួសារចាំបាច់យើងត្រូវដឹងពីបច្ចេកទេសនៃការចិញ្ចឹមដើម្បីជួយថែរក្សាគោឱ្យមានសុខភាពល្អ និងជួយជាកម្លាំងអូសទាញសម្រាប់ប្រើប្រាស់ឱ្យបានយូរអង្វែង ព្រោះគោជាសត្វមានប្រយោជន៍ដ៏សំខាន់ដូចជា:

- ជាកម្លាំងអូសទាញក្នុងការងារកសិកម្ម
- ផ្តល់សាច់ និង ទឹកដោះសម្រាប់ជាអាហារ និង ជម្រុញការលូតលាស់របស់សារពាង្គកាយ
- សម្រាប់ផលិតកូន និង ទុកបន្តពូជ
- ផ្តល់លាមកសម្រាប់យកទៅធ្វើជាជីកំប៉ុស៍សម្រាប់ដាក់ស្រែចំការ ដំណាំផ្សេងៗដើម្បីបង្កើនទិន្នផល
- ផ្តល់ជាស្បែកសម្រាប់ធ្វើឧបករណ៍ផ្សេងៗ ដូចជា កាតាប ស្បែកជើង ខ្សែព្រ័ត្រធ្វើស្គរធំជាដើម។
- ជាពិសេសពេលថ្មីនេះ គេយកលាមកគោលាយជាមួយទឹក រួចបញ្ចូលបង្កន់ជីវឧស្ម័ន ដើម្បីយកឧស្ម័នសម្រាប់ដុតចំអិនអាហារ។

ដើម្បីឱ្យការចិញ្ចឹមគោទទួលបានជោគជ័យ យើងត្រូវយកចាប់អារម្មណ៍លើចំណុចសំខាន់មួយចំនួនដូចជា:

- ជម្រក ឬ ក្រោល
- ការជ្រើសរើសពូជ
- ចំណី និង ការផ្តល់ចំណី
- ការថែទាំ និងការការពារជម្ងឺ
- ជម្ងឺ និង ការព្យាបាល

## ១. សំណង់ក្រោល ឬ ជម្រកៈ

- ទីកន្លែងៈ ត្រូវសង់នៅលើដីទួល មានខ្យល់អាកាសចេញចូល និង ស្រួលបង្ហូរទឹក ហើយត្រូវនៅ ក្រោមខ្យល់ដើម្បីកុំឱ្យធុំក្លិន។
- ទិសៈ ត្រូវសង់ក្រោលគោ-ក្របី បណ្តោយថ្ងៃ។
- របៀបសង់ៈ កម្រាលក្រោលត្រូវមានចំណោទដើម្បីងាយស្រួលបញ្ចេញទឹក
    - ❖ ផ្ទៃក្រឡាៈ

- ➢ គោ ក្របី ញី ៤ ម² ក្នុង ១ ក្បាល
- ➢ មេ គោ ក្របី បំបៅកូនៈ ៨-៩ ម² ក្នុង ១ ក្បាល
- ➢ កូនគោ ក្របីៈ ២-២.៥ ម² ក្នុង ១ ក្បាល

❖ កម្ពស់ក្រោលៈ

- ➢ គោ ក្របី ឈ្មោលៈ ១.៤-១.៦ ម² ក្នុង ១ ក្បាល
- ➢ គោ ក្របី ញីៈ ១-១.២ ម² ក្នុង ១ ក្បាល។

- ត្រូវមានទ្រុងសម្រាប់ដាក់ស្មៅ ចំបើងដើម្បីទុកឱ្យគោ ក្របី ស៊ីបន្ថែម (បណ្តោយៈ ១.៥ម៉ែត្រ ទទឹងៈ ១ម៉ែត្រ កម្ពស់ៈ ០.៥ម៉ែត្រ) ត្រូវមានរណ្តៅរឺ រោងសម្រាប់ដាក់លាមក សង់ឱ្យឆ្ងាយពីក្រោល (បណ្តោយៈ ៤ម៉ែត្រ ទទឹងៈ ២ម៉ែត្រ កម្ពស់ៈ០.៧ម៉ែត្រ)។



## ២. ការជ្រើសរើសពូជគោ

- អំពីរូបរាងៈ មានមាឌធំ មានភាពរហ័សរហួន ស្លូត។
- ផ្នែកដទៃទៀតៈ
  - ➢ ក្បាលៈ ធំល្មមតែវែង ថ្ងាស់ទូលាយ មាត់ទូលាយ ច្រមុះសើម ស្លឹកត្រចៀកធំល្មម ធ្មេញសស្មើជិត គ្មានប្រេះស្រាំ ស្នែងស្មើ។

- ក និងដងខ្លួនៈ កវែងល្មម ទ្រូងទូលាយ ស្មាទូលាយ ខ្នងវែងត្រង់ ឬកោងឡើងលើបន្តិច ឆ្អឹងជំនីរធំមូល គូទទូលាយ។
- ជើងៈ ជើងទាំងបួនធំត្រង់ ជើងមុខទាំងពីរឃ្លាតត្រង់គ្នា ក្បាលជង្គង់មូល ភ្លៅក្រោយទាំងពីរធំវែង ក្រចកជើងជិតរឹងមាំ។
- កន្ទុយៈ ធំ
- ស្បែកៈ រលោង ស្តើងល្មម រោមរាបជាប់ស្បែក
- ប្រដាប់បន្តពូជៈ
  - គោ ក្របី ឈ្មោល មានពងទាំងពីរធំស្មើ
  - គោញីៈ ក្រសោមដោះធំ សរសៃឈាម លើដោះលេចចេញច្បាស់ ក្បាលដោះធំស្មើ ឃ្លាតពីគ្នា។



កន្សោមដោះធម្មតា



ពងស្វាសដែលមានទម្រង់ល្អ

**២-១-អាយុរបស់គោៈ**

យើងអាចប៉ាន់ស្មានអាយុគោបានច្បាស់នៅពេលវាមានអាយុ ១៨ ខែឡើងទៅដោយសម្គាល់តាមរយៈការផ្លាស់ប្តូរធ្មេញរបស់វាដែលមានចំនួន ៨ នៅផ្នែកខាងមុខ និងជួរក្រោម។ គោមានធ្មេញពីរប្រភេទ គឺធ្មេញទឹកដោះ និងធ្មេញចាស់ (ធ្មេញបន្លាស់)។ ធ្មេញចាស់ ឬធ្មេញបន្លាស់ដុះជំនួសធ្មេញទឹកដោះម្តងពីរៗ ដោយផ្តើមចេញពីចន្លោះកណ្តាលទៅ ហើយមានទំហំធំជាងធ្មេញទឹកដោះ។



- ពេលអាយុ ១៨ខែ វាមានធ្មេញចាស់ ២ ដុះនៅចន្លោះកណ្តាលធ្មេញទឹកដោះចំនួន ៦។
- ពេលអាយុ ២ឆ្នាំ វាមានធ្មេញចាស់ ៤ ដុះនៅចន្លោះកណ្តាលធ្មេញទឹកដោះចំនួន ៤។
- ពេលអាយុ ៣ឆ្នាំ វាមានធ្មេញចាស់ ៦ ដុះនៅចន្លោះកណ្តាលធ្មេញទឹកដោះចំនួនន ២។



- ពេលអាយុ ៤ឆ្នាំ វាមានធ្មេញចាស់ ៨។
- អាយុលើសពី ១០ ឆ្នាំ

**២-២-ការជ្រើសរើសមេគោសម្រាប់បន្តពូជៈ**

- មានរូបរាងស្អាត សុខភាពល្អ
- មេគោត្រូវមានសុខភាពល្អ មានជើងមាំ ឈរត្រង់ពេលមើលពីចំហៀង ពីមុខ និងពីក្រោយ។ ពេលដើរត្រូវនៅលើខ្សែត្រង់ទៅមុខ មិនត្រូវជើងវៀចចេញ ឬវៀចចូលឡើយ។ គោដើរជើងវៀចអាចឱ្យគោងាយសិកក្រចកហើយក្លាយជាដំបៅ។ ក្រចកគោត្រូវស្របគ្នា មិនត្រូវញែកចេញពីគ្នាឡើយ។
- មានដោះល្អ មានចុងដោះស្មើល្អគ្រប់ទាំងបួន ។ ចំពោះគោយកទឹកដោះត្រូវមានកន្សោមដោះធំ
- តាមធម្មតាមេគោអាចបន្តពូជបាននៅពេលដែលវាមានអាយុពី ២,៥ ទៅ ៣ ឆ្នាំ។
- មេគោរៀបរកឈ្មោលត្រូវថែរក្សាឱ្យបានល្អ និង ផ្តល់ចំណីឱ្យបានគ្រប់គ្រាន់។

**២-៣-ការជ្រើសរើសគោបាដើម្បីបង្កាត់ៈ**

- ត្រូវជ្រើសរើសគោបាដែលមានប្រវត្តិពូជល្អ មានជើងមាំ និងក្រចកល្អ។
- ត្រូវជ្រើសរើសគោបាដែលមានពងស្វាសទំហំស្មើគ្នា ហើយមានអាយុយ៉ាងតិច ៣ ឆ្នាំឡើងទៅ។
- ត្រូវជ្រើសរើសគោបាធំ តែកុំឱ្យធំជាងមេគោពេក ពិសេសចំពោះមេគោកូនដំបូង។
- ត្រូវពិនិត្យឱ្យបានច្បាស់លាស់តើគោនោះធាត់ពេក ឬស្គមពេក?

- ត្រូវពិនិត្យមើល តើម្ចាស់គោបានថែរក្សាគោរបស់គាត់ល្អឬទេ ?
- ត្រូវពិនិត្យតើគោបានេះធ្លាប់ផលិតកូនបានល្អទេនៅក្នុងភូមិ ?
- មិនត្រូវបង្កាត់ជាមួយនឹងបាដែលជាបងប្អូននិងគ្នាទេ
- មិនត្រូវបង្កាត់ជាមួយគោបាដែលពាកមេច្រើនក្នុងមួយអាទិត្យព្រោះកម្លាំងវាខ្សោយ។ តាមធម្មតាគោបាអាចពាក់មេបានល្អក្នុងចំនួន ៧ ទៅ ១០ ក្បាលក្នុងមួយខែ។





ពូជស៊ីមប្រាស

## ៣-ការបង្កកំណើត

### ៣-១-ការបន្តពូជរបស់គោៈ

- តាមធម្មតាមេគោអាចបន្តពូជបាននៅពេលដែលវាមានអាយុពី ២,៥ ទៅ ៣ ឆ្នាំ។
- ចន្លោះពីវដ្តរដូវ ១ ទៅវដ្តរដូវមួយទៀតគឺមានរយៈពេល ២១ ថ្ងៃ។
- គោផើមមានរយៈពេល ២៨០-២៨៥ ថ្ងៃ (៩ ខែ ១០ ថ្ងៃ)។ មេគោខ្លះអាចកើតមុន ១៥ ថ្ងៃ ឬក្រោយ ១៥ ថ្ងៃ ដោយអាស្រ័យទៅលើសុខភាព ការថែទាំ ការផ្តល់ចំណី និងពូជរបស់វា។
- សម្រាប់គោឈ្មោលអាចពាក់ញីក្នុងអាយុ ១៨-២៤ខែ។ ការប្រើប្រាស់គោបាមានប្រសិទ្ធភាពល្អ គឺក្នុងចន្លោះអាយុ ២-៦ ឆ្នាំ។
- នៅប្រទេសកម្ពុជាយើងជាធម្មតា មេគោមានកូន ៣ ឬ ៤ ក្បាល ប៉ុន្តែបើវាមានការថែទាំបានត្រឹមត្រូវសុខភាពល្អ វាអាចមានកូន ៥ ឬ ៦ក្បាលក្នុងមួយជិវិតរបស់វា។

- *ការជ្រើសរើសពេលវេលាសម្រាប់ដាក់បា យកល្អមេគោត្រូវឱ្យមានគភិចាប់ពីខែ វិច្ឆិកា ដល់ មករា គឺជាពេលវេលាល្អបំផុតពីព្រោះពេលនេះសំបូរស្មៅខ្ចី ងាយស្រួលរកចំណីឱ្យវាស៊ី ដើម្បីបំប៉នសុខភាព នៅពេលមានគភិ ។*

## ៣-២- សញ្ញាណនៃការរកឈ្មោលរបស់មេគោះ

- សត្វមិនស៊ីស្មៅទេ
- សត្វជ្រួលច្រាលហើយស្រែករោទិ៍ជាញឹកញាប់
- សត្វព្យាយាមពាក់សត្វដទៃ និង ឈរនៅស្ងៀមពេលគេយកដៃដាក់លើខ្នងវា
- តាមធម្មតាសត្វអន់ចំណី ២-៣ ថ្ងៃ
- មានហូរទឹករំអិលចេញពីប្រដាប់បន្តពូជ
- ប្រដាប់បន្តពូជឡើងក្រហម និងហើម
- តាមធម្មតាសត្វបន្ថយការផ្តល់ទឹកដោះ ១-២ថ្ងៃ មុនពេលរកឈ្មោល
- ពេលវេលាត្រឹមត្រូវសម្រាប់បង្កាត់ៈ បន្ទាប់ពីសត្វញីបង្ហាញការរកឈ្មោលត្រូវចាប់បង្កាត់នៅ ១២-១៨ ម៉ោងក្រោយ ។
- មេគោរកឈ្មោលរយៈពេល ពី ១-២ ថ្ងៃប៉ុណ្ណោះ ផុតរយៈពេលនេះមេគោពុំរកឈ្មោលទៀតឡើយ ។ វានឹងរកឈ្មោលម្តងទៀតបន្ទាប់ពី ២១ថ្ងៃក្រោយមក ។ នេះគឺមកពីខួបរដូវរបស់មេគោដែលមានរយៈពេល ២១ថ្ងៃ ។




## ៣-៣- ថ្ងៃខែបង្កាត់ និងថ្ងៃខែកើតរបស់មេគោៈ

| ថ្ងៃខែបង្កាត់ | | ថ្ងៃខែកើត | | ថ្ងៃខែបង្កាត់ | | ថ្ងៃខែកើត | |
|---|---|---|---|---|---|---|---|
| ខែ | ថ្ងៃ | ខែ | ថ្ងៃ | ខែ | ថ្ងៃ | ខែ | ថ្ងៃ |
| មករា | ១ | តុលា | ១០ | កក្កដា | ៩ | មេសា | ១៧ |
| | ៨ | | ១៧ | | ១៦ | | ២៤ |
| | ១៥ | | ២៤ | | ២៣ | ឧសភា | ១ |
| | ២២ | | ៣១ | | ៣០ | | ៨ |
| | ២៩ | វិច្ឆិកា | ៧ | សីហា | ៦ | | ១៥ |
| កុម្ភៈ | ៥ | | ១៤ | | ១៣ | | ២២ |
| | ១២ | | ២១ | | ២០ | | ២៩ |
| | ១៩ | | ២៨ | | ២៧ | មិថុនា | ៥ |
| | ២៦ | ធ្នូ | ៥ | កញ្ញា | ៣ | | ១២ |
| មិនា | ៥ | | ១២ | | ១០ | | ១៩ |
| | ១២ | | ១៩ | | ១៧ | | ២៦ |
| | ១៩ | | ២៦ | | ២៤ | កក្កដា | ៣ |
| | ២៦ | មករា | ២ | តុលា | ១ | | ១០ |
| មេសា | ២ | | ៩ | | ៨ | | ១៧ |
| | ៩ | | ១៦ | | ១៥ | | ២៧ |
| | ១៦ | | ២៣ | | ២២ | | ៣១ |
| | ២៣ | | ៣០ | | ២៩ | សីហា | ៧ |
| | ៣០ | កុម្ភៈ | ៦ | វិច្ឆិកា | ៥ | | ១៤ |
| ឧសភា | ៧ | | ១៣ | | ១២ | | ២១ |
| | ១៤ | | ២០ | | ១៩ | | ២៨ |
| | ២១ | | ២៧ | | ២៦ | កញ្ញា | ៤ |
| | ២៨ | មិនា | ៦ | ធ្នូ | ៣ | | ១១ |
| មិថុនា | ៤ | | ១៣ | | ១០ | | ១៨ |
| | ១១ | | ២០ | | ១៧ | | ២៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កក្កដា | ១៨<br>២៥<br>២ | មេសា | ២៧<br>៣<br>១០ | | ២៤<br>៣១ | តុលា | ២<br>៩ |

**៣-៤- ការថែទាំមេគោមុន និងក្រោយកើតកូនៈ**

- មុនពេលកើតត្រូវឱ្យមេគោ ក្របី សម្រាក់ពីការងារ ១-២ខែ
- ឱ្យស៊ីស្មៅខ្ចី
- ត្រូវសម្អាតក្រោលឱ្យបានស្អាត
- ក្រោយពេលកើតកូនរួចត្រូវយកទឹកក្តៅអ៊ុនៗ លាយអំបិលហើយលាងសម្អាតដោះ ប្រដាប់បន្តពូជ ។
- កើតបាន ១ ម៉ោងត្រូវឱ្យកូនបៅដោះ
- ឱ្យមេគោសម្រាក់ ១ ខែ ក្រោយពេលបង្កើតកូនរួចហើយឱ្យធ្វើការស្រាលៗ
- ត្រូវផ្តល់ស្មៅ និង ចំណីដែលមានគុណភាពល្អដល់មេ
- ត្រូវផ្តល់ទឹកឱ្យបានច្រើនធ្វើដូចនេះមេអាចផលិតទឹកដោះបានច្រើន ។

**៣-៥- លក្ខណៈពេលមេគោជិតកើតកូនៈ**

ពេលមេគោជិតលើតកូនគេសម្គាល់ដោយៈ

- ឱ្យមេគោសម្រាកពីការងារ ១-២ ខែ មុនពេលកើត
- ពេលកូនជិតកើតពោះរបស់មេគោរីកធំ
- ដោះរីកធំ នឹងមានទឹកដោះតិចៗ ចេញពីចុងដោះ
- ប្រដាប់បន្តពូជរីកធំ និងមានទឹករំអិលចេញមក

ក្នុងលក្ខណៈដូចនេះត្រូវចងមេគោ ហើយយើងត្រូវពិនិត្យមើលអោយបាន ៣-៤ដង ក្នុងមួយថ្ងៃ ក្រែងមានបញ្ហាអ្វីកើតឡើងនៅពេលគោកើតកូន ។

**៣-៦- លក្ខណៈពេលមេគោបង្កើតកូន និងការជួយមេគោៈ**

ជាដំបូងគេសង្កេតឃើញលេចចេញថង់ទឹកភ្លោះរួចបែក បន្ទាប់មកកូនគោត្រូវបានចាប់ផ្តើមកើត ។ ជាមធ្យម មេគោអាចបង្កើតកូនក្នុងរយៈពេលប្រហែល ២ម៉ោង ។ ការកើតរបស់កូនគោក្នុងសភាពធម្មតា

- កូនគោពេលកើតមកគឺក្បាល និង ជើងមុខពីរចេញស្របគ្នាមកមុន
- ឬជើងក្រោយទាំងពីរសណ្តូកត្រង់ស្របគ្នាចេញមក ហើយខ្នងស្របនឹងខ្នងរបស់មេ ។



មេគោប្រហែល ៩០ភាគរយ ពុំមានបញ្ហាពេលបង្កើតកូនទេ។ ប៉ុន្តែប្រសិនបើសម្រាលកូនដោយលំបាកលើសពីរយៈពេល ២ ទៅ ៦ម៉ោងនោះ យើងត្រូវធ្វើការសន្និដ្ឋានពីលក្ខណៈកូនកើតខុសប្រក្រតីដូចជា:

- ចេញជើងមុខមកមុន តែក្បាលបត់ទៅក្រោយ



- ទីតាំងគូថមកមុន(ដោយជើងក្រោយបត់ទៅមុខ)



- ជើងក្រោយទាំងពីចេញមកមុន



- ជើងមុខមួយចេញមកមុន ហើយជើងម្ខាងទៀតបត់ទៅក្រោយ



- ក្បាលចេញមកមុនហើយជើងមុខពីរបត់ទៅក្រោយ



បើជួបប្រទះនូវលក្ខណៈដូចខាងលើនេះយើងត្រូវរត់រកភ្នាក់ងារពេទ្យសត្វភូមិមកជួយជាបន្ទាន់ ។

*មេគោអាចស៊ីសុករបស់វា តែមិនគួរគប្បីឱ្យវាស៊ីសុកឡើយ ។*

**៣-៧- ការជួយកូនគោកំឡុងពេលកើត:**

- បើសិនឃើញភ្នាសស្តើងនៃសុកនៅរុំព័ទ្ធកូននោះយើងត្រូវជូតសម្អាតក្បាលវាជាពិសេសយកម្រាមដៃលូកក្នុងរន្ធច្រមុះមាត់ដោយបារយកកំបោរ ស្លេះរំអិលឱ្យបានឆាប់រហ័សដើម្បីឱ្យកូនគោអាចដកដង្ហើមបាន ។
- បើសិនជាកូនគោនៅមិនទាន់អាចដកដង្ហើមបានទៀត យើងត្រូវផ្លុំខ្យល់ចូលមាត់វា និងរឹតច្របាច់ដើមទ្រូងវា លុះត្រាកូនគោដកដង្ហើម ។
- ជាធម្មតាមេគោវាលិតកូនវាក្រោយពេលកើតរួចទាល់តែកូនវាស្ងួត និងក្រោកដើរបាន ។
- កូនគោកើតរួច យើងត្រូវកាត់ទងផ្ចិតវាចំងាយពីពោះប្រហែល ៥-១០ សម ។ មុនកាត់ត្រូវច្របាច់ឈាមនៅក្នុងទងផ្ចិតនោះឱ្យអស់រួចចងផងដែរ ហើយត្រូវលាបថ្នាំក្រហម ឬអ៊ីយ៉ូត ។ ការធ្វើបែបនេះគឺដើម្បីការពារជម្ងឺរលាកផ្ចិតកូន គោ និង ជម្ងឺ តេតាណូស ។
- ត្រូវជួយឱ្យកូនគោឱ្យបៅទឹកដោះដំបូងរបស់មេវាកុំខានឱ្យសោះ ។
- បើសិនកូនគោខ្សោយមិនអាចក្រោកឈរបៅដោះដោយខ្លួនឯងបានយើងត្រូវរឹតយកទឹកដោះនោះពីមេវាទៅបញ្ចុកកូន ។ សូមចំណាំ ទឹកដោះដំបូងមានពណ៌លឿង និងខាប់ជាងទឹកដោះធម្មតាវាជាចំណីដ៏សំខាន់សម្រាប់កូនកើតដំបូង ។

### ៣-៨- ការថែទាំកូនគោទើបកើត

- ត្រូវសម្អាតរំអិល ភាពកខ្វក់ចេញពីមាត់ និងច្រមុះ ធ្វើដូចនេះសត្វទើបកើតដកដង្ហើមបានស្រួល
- កាត់ទងផ្ចិតប្រហែល ៣-៥ ស.ម ពីផ្ចិត
- ត្រូវឱ្យមេលិតកូនទើបកើត វាអាចជួយឱ្យមានភាពស្និតស្នាលរវាងមេ និង កូន។
- ជម្រុញឱ្យកូនគោបៅដោះមេវាឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបានព្រោះថា ទឹកដោះដំបូងអាចជួយការពារកូនសត្វទប់ទល់និងជម្ងឺ ហើយធ្វើឱ្យសត្វមានការធំធាត់យ៉ាងឆាប់រហ័សនិងមានសុខភាពល្អ។
- កូនសត្វអាយុចាប់ពី ១ ខែ ឡើងទៅត្រូវបង្រៀនវាឱ្យស៊ីស្មៅ
- ចាប់ពីអាយុ ៨-១០ ខែ គេចាប់ផ្តើមខ្ទះច្រមុះ
- ជាទូទៅគេនិយមផ្តាច់ដោះនៅអាយុ ៥-៦ ខែ ពេលខ្លះរហូតដល់រយៈពេល ១ ឆ្នាំ។

## ៤. ការវាស់ទម្ងន់របស់គោ:

ដើម្បីដឹងទម្ងន់របស់គោយើងអាចអនុវត្តន៍តាមរូបមន្តខាងក្រោម:

ទម្ងន់គោ (គិតជាគីឡូក្រាម) = (ទំហំទ្រូង X ទំហំទ្រូង X ប្រវែងដងខ្លួន) / ៣០០ X 0.៩៥

## ៥- ចំណី ការផ្តល់ចំណី និងតម្រូវការទឹករបស់គោ:

### ៥-១- ចំណីរបស់គោ:

ជាការល្អប្រសើរណាស់ បើសិនជាមានការយកចិត្តទុកដាក់លើការដាំដំណាំដែលអាចធ្វើជាចំណីគោ ឬដាំស្មៅពូជល្អៗ ដើម្បីយកធ្វើជាចំណីគោ ដូចជា កន្ទុំថេត ស្លឹកអង្គារដី ដំឡូងមី ស្មៅជ័រ និងចេះធ្វើចំបើងផ្អាប់ជាដើម


ដើមកន្ទុំថេត


រូបភាពដើមដំឡូងឈើ









រូស៊ី (Ruzi)

ស្ទីឡូ ១៨៤(Stylo-184)



ស្មៅណាពៀ (Napier Grass )

**៥-២-រូបមន្តផ្សំចំណីសម្រាប់គោៈ**

កសិករអាចសាកល្បងការផ្សំវត្ថុធាតុដើមដូចខាងក្រោមជា ចំណីបំប៉នសម្រាប់គោ

| ល.រ | វត្ថុធាតុសម្រាប់ផ្សំចំណី | បរិមាណ (គ.ក្រ) |
|---|---|---|
| ១ | កន្ទក់ | ១២ |
| ២ | ចំណិតមើមដំឡូងស្ងួត | ៧ |
| ៣ | ស្លឹកដំឡូងមីក្រៀម (ទាំងស្លឹក ធាង ដើម) | ៣ |
| ៤ | ជីអ៊ុយរេ | ០,៣ |
| ៥ | ស្ករត្នោត | ០,២៥ |

**៥-៤-ទឹកៈ** ទឹកនៅក្នុងខ្លួនសត្វមានតួនាទីៈ

- ដឹកនាំជីវជាតិចូលទៅក្នុងឈាម
- រក្សាសីតុណ្ហភាពដងខ្លួន
- ដើម្បីផលិតសាច់ ទឹកដោះ
- ជួយសម្រួលដល់ការរំលាយអាហារ
- ផលិតឈាម
- បញ្ចេញសារធាតុពុលចេញពីរាង្គកាយ ( ដឹកនាំកាកសំណល់ចេញក្រៅ )
- ដើម្បីជៀសវាងជម្ងឺតម្រងនោម ដូចជានោមមានពណ៌ក្រហម
- ជាសារធាតុរំអិលដែលជួយកុំឱ្យរលាកសន្លាក់
- ជួយបន្សាបជាតិពុល

តម្រូវការទឹករបស់សត្វមានការប្រែប្រួល ហើយវាអាស្រ័យទៅលើៈ

- កត្តាសត្វ (ប្រភេទ ទម្ងន់ សភាពរូបរាង របបចំណី ជម្ងឺ )
- កត្តាមជ្ឈដ្ឋានជុំវិញ (សីតុណ្ហភាព សំណើម ខ្យល់)
- កត្តាទឹក (ទីតាំង គុណភាព បរិមាណ សីតុណ្ហភាព )

តម្រូវការទឹករបស់គោៈ គោត្រូវការទឹកទៅតាមទម្ងន់

| ទម្ងន់គិតជា គីឡូក្រាម | តម្រូវការទឹកជាមធ្យម គិតជាលីត្រ /ថ្ងៃ |
|---|---|
| ៥០ | ៦-៧ |
| ៧០ | ៧-៩ |
| ៩០ | ១០-១១ |
| ១២០ | ១៤-១៦ |
| ១៥០ | ១៨-២០ |
| ១៩០ | ២០-២៥ |
| ៣៥០ | ២៥-៣៥ |
| ៤៥០ | ៣៥-៤៥ |
| ៥៤០-៧៣០ | ៤៥-១១០ |

តាមធម្មតាជាមធ្យមគោត្រូវការផឹកទឹកក្នុងមួយថ្ងៃ ៣០-៤០លីត្រ។ ម្យ៉ាងទៀតគោក្របីវាក៏ត្រូវការអំបិលខ្លះដែរ ដូចនេះពេលអោយទឹកគោក្របីត្រូវយកអំបិលលាយក្នុងទឹកពី ៤០-៥០ក្រាម ក្នុងទឹកមួយធុង។ ការផ្តល់ទឹកមិនបានគ្រប់គ្រាន់អោយគោអាចនាំអោយគោអន់ចំណី និង ងាយទទួលជំងឺផ្សេងៗ។

## ៦- ការថែទាំ និងការការពារជម្ងឺៈ

តារាងពេលវេលាដែលត្រូវចាក់ថ្នាំការពារចំពោះគោ

| ប្រភេទថ្នាំការពារជម្ងឺ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អ៊ុតក្លាម | — | — | — | | | | | | | | — | — |
| សារទឹក | — | — | — | | | | — | — | | | — | — |
| ឈាមខ្មៅ | — | — | — | — | | | | | | | | |
| បូសខ្យល់ | — | | | | | | | | | — | — | — |

## ៧- ជម្ងឺ និងការព្យាបាលៈ

### ៧-១- ជម្ងឺទូទៅៈ

#### ៧-១-១-គោមិនស៊ីចំណីៈ

**រោគសញ្ញាៈ** គោមិនស៊ីចំណី ឬ ស៊ីតិចតួច មិនទំពារអៀង ស្រកទម្ងន់ គោខ្សោយដំណើរទ្រេតទ្រោត ឈរទ្រឹង ភ្នែកមមី។

**មូលហេតុៈ** គោឈឺចាប់ក្នុងមាត់ដោយសារដំបៅ ចំណីខ្វះគុណភាព ប្រើប្រាស់គោច្រើនពេក។ គោឈឺដោយជម្ងឺ ទូទៅផ្សេងៗដូចជា គ្រុន ក្ស្បេន ហើមពោះ រាគជាដើម។ គោឈឺដោយជម្ងឺឆ្លង បង្កដោយវីរុស មេរោគ ឬ ព្រូន។
**ការព្យាបាលៈ** គេអាចធ្វើទឹកនោមផ្អាប់ឱ្យគោផឹក ដោយប្រើពាងដែលមានចំណុះប្រហែល ២០លីត្រ រួចលាយទឹកនោមមនុស្ស ១០-១៥ លីត្រ សំបកស្ដៅ 0,៥ គីឡូក្រាម វល្លិពេជ្រឈ្មោល 0,៥ គីឡូក្រាម ត្នោតទុំ២-៣ផ្លែ។ ត្រាំរយៈពេល ៧-១០ ថ្ងៃ រួចច្រកឱ្យគោផឹកម្ដង 0,៥ លីត្រ ព្រឹក-ល្ងាច គោត្រូវឧស្សាហ៍លាងទឹក។

### ៧-១-២-គោគ្រុនៈ

**រោគសញ្ញាៈ** គោមិនសូវស៊ីចំណី ឬមិនទំពារអៀ គោស្រេកទឹកផឹកទឹកច្រើន គោក្ដៅខ្លួន រោមប៉ះ ច្រមុះ ស្ងួត ភ្នែកមមី។
**មូលហេតុៈ** ដោយសារអាកាសធាតុប្រែប្រួល មកពីប្រើប្រាស់សត្វហួសកំលាំង គោមានមេរោគនៃជម្ងឺឆ្លងដូចជា អុតក្ដាម សារទឹក បុសខ្យល់ ឈាមខ្មៅ ឬ បណ្ដាលជម្ងឺផ្សេងទៀត។
**ការព្យាបាលៈ**

- ចាក់ថ្នាំប៉េនីស៊ីលីន លាយជាមួយស្ត្រិបតូមីស៊ីន។
- ស្ងោរស្លឹកអំពិលមួយក្ដាប់ និង ផ្លែខ្ចីប្រហែល ២,៥ ខាំ ជាមួយទឹកកន្លះលីត្រ ឱ្យពុះរយះពេល ១៥ នាទី រួចច្រកឱ្យគោផឹក ២ ដងក្នុងមួយថ្ងៃ ផឹករយះពេល ២-៣ ថ្ងៃ ។
- ស្ងោរស្លឹកស្ដៅមួយក្ដាប់ក្នុងទឹកមួយលីត្រ រយះពេល ១៥នាទី រួចច្រកឱ្យគោផឹក ច្រកពីរដងក្នុងមួយថ្ងៃ។
- ស្ងោរស្លឹក និង សំបកសាវម៉ាវព្រៃ ១ក្ដាប់ ជាមួយទឹក ៣លីត្រ រយះពេល ៣0នាទី ច្រកឱ្យគោផឹក ២ ដងក្នុង ១ ថ្ងៃ ។

### ៧-១-៣-ជម្ងឺគោក្សៀនៈ

**រោគសញ្ញាៈ** គោមិនស៊ីចំណី គោប្រឹងបន្ទោរបង់តែមិនចេញលាមក លាមករឹងស្ងួត។
**មូលហេតុៈ** ស៊ីចំណីសំបូរធាតុសរសៃច្រើន ផ្ដល់ទឹកឱ្យគោមិនបានគ្រប់គ្រាន់ ការកន្ត្រាក់ពោះវៀនខ្សោយ ដោយខ្វះជាតិអំបិលក្នុងចំណី។
**ការព្យាបាលៈ** ដាំទឹកអំបិលប្រៃល្មមរួចសុលឱ្យគោ ឬ សុលដោយអំពិលទុំ ឬ សុលសាប៊ូដុំ។ គេក៏អាចលូកដៃបាអាចម៍ចេញពីគូតគោផងដែរ។

### ៧-១-៤-ជម្ងឺហើមពោះ

**រោគសញ្ញាៈ** គោមានពោះរីកធំ ពិសេសផ្នែកខាងពោះបាយខាងឆ្វេង។ គោដេកងើបៗ មិនស៊ីចំណី មិនទំពារអៀង។ គោយកជើងក្រោយធាក់ពោះ។ គោដង្ហក់ដង្ហើមញាប់ ជីពចរញាប់។
**មូលហេតុៈ** គោស៊ីស្មៅខ្ចីច្រើនពេក ឬ ការផ្លាស់ប្ដូរចំណីឆាប់ពេក។ គោស៊ីចំណីដោយរុក្ខជាតិពុល។ គោទល់លាមក។ គោផឹកទឹកដោយជាតិគីមី ។ ភាគច្រើននៃជំងឺហើមពោះគោ គឺបណ្ដាលមកពីបាក់តេរីដែលមាននៅក្នុងពោះបាយគោ

បញ្ចេញឧស្ម័យនៅពេលដែលវាមានប្រតិកម្មជាមួយស្មៅ ។

**ការព្យាបាលៈ** បើទល់លាមក យើងត្រូវសុល ឬ បាលាមកចេញ។ ករណីធ្ងន់ធ្ងរខ្លាំងត្រូវចាក់ទំលាយពោះគោយកខ្យល់ចេញដោយប្រើម្ជុលត្រ័រការ ឬ កូនកាំបិតរួចដោតជំនួសដោយបំពង់ឬស្សី ដែលមានទំហំ ២-៣ សង់ទីម៉ែត្រ ។

### ៧-១-៥-ជម្ងឺរាគៈ

**រោគសញ្ញាៈ** គោមានលាមករាវ ជួនកាលលាយសំបោរ ឬ ឈាម។ ស្បែកស្ងួត គោស្គម អន់ចំណី មិនទំពារ អៀងច្រមុះស្ងួត ភ្នែកមមី ។

**មូលហេតុៈ** ស៊ីស្មៅខ្ចីច្រើនពេក។ គោរាគបណ្តាលពីមេរោគនៃជំងឺឆ្លង។ រាគបណ្តាលមកពីព្រូន។ រាគបណ្តាលពីជាតិពុលក្នុងចំណី។

**ការព្យាបាលៈ**

- បើសិនជាគោរាគធម្មតាដោយមិនក្តៅខ្លួន យើងគ្រាន់តែស្ងោរស្លឹកត្របែកចំនួន 0,៥ គីឡូក្រាម ជាមួយទឹក ១ លីត្រច្រកឱ្យគោផឹក ២ដងក្នុង ១ថ្ងៃ។ យើងអាចប្រើស្លឹកទឹកដោះគោក៏បានបើគ្មានស្លឹកត្របែក ។
- បើសិនជាគោរាគក្នុងរយះពេលយូរ ហើយស្គមត្រូវសន្និដ្ឋានលើជំងឺព្រូន។ ត្រូវចាក់ថ្នាំទំលាក់ព្រូន
- បើសិនជារាគហើយក្តៅ និងមានរោគសញ្ញាផ្សេង១ទៀត ត្រូវប្រើពពួកថ្នាំអង់ទីប៊ីយ៉ូទិចដូចជា អុកស៊ីគ្លីន អុកស៊ីតេត្រាស៊ីគ្លីន ស្រ្តិបតូមីស៊ីនជាដើម។
- ពេលមានជម្ងឺផ្ទុះឡើង ត្រូវចងសត្វទុកមួយកន្លែងរួចរកស្មៅឱ្យវាស៊ី។

ជំងឺឆ្លងដែលជួបប្រទះញឹកញាប់នៅប្រទេសយើងមាន សារទឹក អុតក្តាម ឈាមខ្មៅ បុសខ្យល់ និង អឺឌែមម៉ាឡាំង។

## ៧-២-ជម្ងឺ គោ ក្របី សំខាន់ៗ

### ៧-២-១- ជម្ងឺសារទឹក (Haemoraghic Septicaemia, Pasterellosis):

ជម្ងឺសារទឹកជាជម្ងឺឆ្លងដ៏ឆាប់បំផុតមានការវិវត្តនិយ៉ាងឆាប់រហ័សហើយវាជាជម្ងឺបង្កឡើងដោយបាក់តេរី។ ជម្ងឺនេះច្រើនកើតលើសត្វ គោ ក្របី ចៀម ពពែ និង ជ្រូក ហើយច្រើនកើតនៅដើមរដូវវស្សា។

**រោគសញ្ញាៈ**

- គ្រុនក្តៅខ្លាំង ស្ងួតចុងច្រមុះ សត្វមិនទំពារអៀង
- សត្វពិបាកដកដង្ហើម
- ជាញឹកញាប់គេសង្កេតឃើញសត្វដកដង្ហើមតាមមាត់
- មានសំលេងស្អារៗចេញពីបំពងក នៅពេលដកដង្ហើមម្តងៗ
- សត្វហៀរទឹកមាត់ ហៀរសំបោរ
- ហើមករ លៀនអណ្តាតចេញមកក្រៅ

- ហើមពោះ ហើយសត្វអាចស្លាប់យ៉ាងឆាប់រហ័ស នៅក្នុងរយៈពេលប៉ុន្មានម៉ោងក្រោយពីមានរោគសញ្ញាទាំងនេះលេចឡើង ។
- រឹងជើងក្រោយទាំងពីរ ។

**ការចម្លងជម្ងឺៈ**

- តាមរយៈការប៉ះពាល់សារធាតុរាវរបស់សត្វឈឺដូចជា ទឹកមាត់ សំបោរ
- ការយកចំណី សម្ភារៈ ដែលសត្វឈឺ ស៊ី ឬ ប្រើប្រាស់ យកទៅឱ្យសត្វជា ស៊ី ឬ ប្រើ
- តាមរយៈការប៉ះពាល់សត្វឈឺ ហើយ ទៅប៉ះពាល់សត្វជា
- តាមរយៈការទិញសាច់សត្វដែលកើតជម្ងឺ ឬ ចរាចរសត្វឈឺ

**ការការពារៈ**

- ត្រូវចាក់វ៉ាក់សាំងការពារ ជម្ងឺសារទឹកឱ្យបាន ២ដង ក្នុង១ឆ្នាំ គឺនៅដើមរដូវធ្វើស្រែ ចំការ នៅចុងខែមេសា និង ចុងខែវិច្ឆិកា ។
- ត្រូវដាក់សត្វឈឺឱ្យនៅឆ្ងាយពីសត្វជា ដើម្បីងាយស្រួលក្នុងការព្យាបាល
- ហាមយកសម្ភារៈ ចំណីរបស់ឈឺទៅឱ្យសត្វជា
- ហាមចរាចរសត្វ ឬ លក់សត្វដែលឈឺ
- ហាមចរាចរ ឬឆ្លងកាត់កន្លែងដែលផ្ទុះជម្ងឺ
- កប់សត្វងាប់ ឬដុតកំរាលរបស់វាចោល

**ការព្យាបាលៈ**

- អំពីដិចសាឡោន (Ampidexalone): 1cc/10kg
- ទ្រីស៊ុលម៊ិច (Trisulmix): 1cc/10kg
- រ៉េម៉ាស៊ីគ្លីន (Remacycline L.A): 1cc/20kg
- ប៊ីយ៉ូឌីល (Biodyl): 1cc/10kg

**៧-២-២- ជម្ងឺ អ៊ុតក្តាម (Foot and Mouth Disease)**

ជាជម្ងឺដែលបង្កឡើងដោយវីរុស ហើយជម្ងឺនេះច្រើនកើតលើសត្វដែលមានចង្កែកជើងពីរដូចជាសត្វគោ ក្របី ចៀម ពពែ និង ជ្រូក ។

**រោគសញ្ញាៈ**

សត្វដែលកើតជំងឺនេះបង្ហាញរោគសញ្ញា ដូចខាងក្រោម

- សត្វអន់ចំណី ហើយកំដៅឡើងក្តៅ

- ហៀរទឹកមាត់ បែកពពុះមាត់

- មានច្រាំង នៅលើអណ្តាត ហើយមានពងបែកនៅលើអណ្តាត

- មានពងបែកនៅតាមអញ្ចាញធ្មេញ

- មានពងបែកនៅលើកន្សោមដោះ ឬ ចុងដោះដែលមិនអាចបំបៅកូនបាន

- មានពងបែកនៅលើគែមក្រចកជើងដែលបណ្តាលឱ្យមានដំបៅរលួយក្រចកហើយធ្វើឱ្យសត្វពិបាកដើរ

- ចំពោះមេជើមធ្វើឱ្យរលូតកូន

**ការចម្លងជម្ងឺ:**

- តាមរយៈការប៉ះពាល់សារធាតុរាវរបស់សត្វឈឺដូចជា ទឹកមាត់ សំបោរ

- ការយកចំណី សម្ភារៈដែលសត្វឈឺ ស៊ី ឬ ប្រើប្រាស់យកទៅឱ្យសត្វជា ស៊ី ឬប្រើ

- តាមរយៈការប៉ះពាល់សត្វឈឺ ហើយទៅប៉ះពាល់សត្វជា

- តាមរយៈការទិញសាច់សត្វដែលកើតជម្ងឺ ឬ ចរាចរសត្វឈឺ

**ការការពារ:**

- ចាក់វ៉ាក់សាំងការពារជម្ងឺ **អ៊ុតក្តាម** រៀងរាល់ ៦ ខែ។

- ត្រូវដាក់សត្វឈឺឆ្ងាយពីសត្វជា

- ហាមយកសម្ភារៈរបស់សត្វឈឺ ស្មៅទៅឱ្យសត្វជា

- ហាមចរាចរសត្វ ឬ លក់សាច់សត្វដែលមានជម្ងឺ

- ហាមចេញ-ចូលកន្លែងដែលផ្ទុះជម្ងឺ

- ត្រូវថែរក្សាសត្វឱ្យមានសុខភាពល្អ

- កប់សត្វងាប់ ឬ ដុតកំរាលរបស់វាចោល

**ការព្យាបាល:**

ជម្ងឺអ៊ុតក្តាមជាជម្ងឺគ្មានថ្នាំព្យាបាលទេ។ ប៉ុន្តែគេអាចចាក់ថ្នាំមួយចំនួនដើម្បីទប់ស្កាត់ការរីកសាយភាយ នៃជម្ងឺឱកាសនិយម។

**ករណីទី ១**

- ប៉េនីឌីអេចអែស (Peni DHS): 1cc/10 kg

- ដិចសារគ័រទីល (Dexacortyl): 1cc/20 kg

- បាញ់ថ្នាំតេត្រាវ៉េតលើដំបៅ (Tetravet)

**៧-២-៣-ជម្ងឺ បូសខ្យល់ (Blackleg)**

**រោគសញ្ញាៈ**

- រោគសញ្ញាដំបូងនៃជម្ងឺនេះគេសង្កេតឃើញសត្វមានអាការៈ ឈឺជើង ខ្ចកជើង
- ហើមប៉ោងសាច់ដុំនៅត្រង់ ស្មារ ត្រគាក ទ្រូង ខ្នង ។ នៅកន្លែងហើមប៉ោងនេះមានសភាពក្តៅ ហើយក្រោយមកប្រែជាត្រជាក់ និងឈឺចាប់ខ្លាំង ។
- មានឮសូរសំលេងក្រិបក្រៀប ដូចជាពពុះខ្យល់ នៅកន្លែងហើមប៉ោង
- នៅកន្លែងប៉ោងហើមមានពណ៌ជាំខ្មៅ ហើយស្ងួត ។
- ពិបាកដកដង្ហើម
- ពិបាកដើរ

**ការចម្លងជម្ងឺ**

- ឆ្លងតាមរយៈការស៊ីស្មៅដែលដុះនៅលើដីមានមេរោគរបស់ជម្ងឺនេះ
- ឆ្លងតាមរយៈមុខរបួសរបស់សត្វជាដែលប្រឡាក់ទៅនឹងដីដែលមានផ្ទុកមេរោគ

**វិធានការការពារៈ**

- ត្រូវចាក់វ៉ាក់សាំងការពារឱ្យបានទៀងទាត់ ។ ចំពោះកូនគោដែលមានអាយុចាប់ពី ៣ខែ ។
- សត្វដែលស្លាប់ត្រូវកប់ រឺ ដុតចោល
- ធ្វើអនាម័យទ្រុង
- បំបែកសត្វឈឺចេញពីសត្វជា
- មិនត្រូវផ្តល់ចំណី ស្មៅ រឺ លែងសត្វឱ្យទៅស៊ីនៅតំបន់ផ្ទុះជម្ងឺ
- ហាមចរាចរសត្វ ទិញ ឬ លក់ ពីកន្លែងមួយទៅកន្លែងមួយទៀតនៅពេលមានផ្ទុះជម្ងឺ

**ការព្យាបាលៈ**

- បេនីឌីអេចអែស (PeniDHS): 1cc/10kg
- អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline): 1cc/10kg
- ប៉ារ៉ារីន ១០០០ (Pararine 1000): 1cc/10kg

**៧-២-៤-ជម្ងឺ ឈាមខ្មៅ (Anthrax)**

**រោគសញ្ញាៈ**

សត្វដែលកើតជម្ងឺនេះស្លាប់ដោយមិនមានបង្ហាញរោគសញ្ញាអ្វីឡើយ ។ ពេលខ្លះបានបង្ហាញរោគសញ្ញាមួយ

ចំនួនដូចជា សត្វឈឺភ្លាម កម្តៅឡើងក្តៅ ដកដង្ហើមញាប់ ញ័រញាក់ ដំណើរទ្រេតទ្រោត គ្រប់ភ្នាសស្លេីងទាំងអស់ឡើងក្រហម ហើយមានហូរឈាមតាម រន្ធញើស រន្ធច្រមុះ រន្ធគូទ ប្រដាប់បន្តពូជ តាមមាត់ ហើយឈាមមិនកក។ គេសង្កេតឃើញសត្វស្លាប់ ៥ ថ្ងៃក្រោយពីឆ្លងជម្ងឺនេះ ហើយសាកសពមានសភាពទន់។

**ការចម្លងជម្ងឺ:**

- ការឆ្លងជម្ងឺនេះតាមមុខរបួស ឬ តាមរយៈការស៊ីចំណី ឬ ស្មៅដែលមានមេរោគ
- សាកសពសត្វដែលស្លាប់ដោយសារជម្ងឺឈាមខ្មៅ និងកន្លែងធ្វើការវះកាត់សាកសពសត្វនោះគឺជាប្រភពនៃការចម្លងជម្ងឺយ៉ាងសំខាន់ព្រោះដោយសារតែសត្វ ឬ មនុស្សយកសាច់សត្វស្លាប់នេះមកបរិភោគ និងមេរោគអាចរស់នៅកន្លែងនេះបានរហូតដល់ ២០ ឆ្នាំ ។ ការឆ្លងរាលដាលជម្ងឺនេះច្រើនកើតឡើងនៅរដូវវស្សា។

**វិធានការការពារ:**

ដើម្បីទប់សាត់ការរីករាលដាលជម្ងឺនេះគឺ

- ត្រូវអនុវត្តន៍កម្មវិធីចាក់ថ្នាំការពារឱ្យបានទៀងទាត់
- មិនត្រូវបរិភោគ ឬ វះកាត់សាកសពសត្វដែលស្លាប់ដោយសារជម្ងឺឈាមខ្មៅឡើយ។
- ត្រូវដុតសាកសពសត្វ ឬ កប់ក្នុងរណ្តៅឱ្យបានជ្រៅ និង ដោយមានរោយកំបោរ។
- ត្រូវធ្វើរបងការពារកន្លែងកប់សាកសពដើម្បីការពារសត្វបំផ្លាញ។
- រាល់សម្ភារះដែលប្រឡាក់ឈាមសត្វ ដី កន្លែងដែលសត្វសាប់ និង ឈាមចេញពីសាកសពគួរតែដុត។

**ការព្យាបាល:**

- បេនីឌីអេចអែស (PeniDHS): 1cc/10kg
- អុកស៊ីតេត្រាស៊ីគីន (Oxytetracycline): 1cc/10kg

**ការប្រុងប្រយ័ត្ន:**

ការត្រួតពិនិត្យសាកសពសត្វដែលសង្ស័យថាកើតជម្ងឺឈាមខ្មៅ គឺជាការនាំឱ្យមានគ្រោះថ្នាក់បំផុត។ អ្នកពិនិត្យគួរគប្បីកុំវះកាត់សាកសព ហើយជៀសវាងកុំប៉ះពាល់ផ្ទាល់នូវអ្វីដែលចេញពីខ្លួនសត្វ ហើយកុំយកសាច់សត្វដែលកើតជម្ងឺឈាមខ្មៅទៅបរិភោគ ព្រោះវាបណ្តាលឱ្យគ្រោះថ្នាក់ដល់ស្លាប់។ ត្រូវកប់សាកសពសត្វដែលកើតជម្ងឺឈាមខ្មៅក្នុងរណ្តៅយ៉ាងជ្រៅ ហើយបាចកំបោរការពារ ឬអាចដុតកម្ទេចចោល។

### ៧-៣- ជម្ងឺបង្កឡើងដោយបរាសិតៈ

#### ៧-៣-១-ជម្ងឺដង្កូវថ្លើមៈ

**រោគសញ្ញាៈ**

- សត្វឈឺ ស៊ី ផឹកជាធម្មតា តែចេះតែស្គមទៅៗ ខ្វះឈាម
- ជួនកាលរាគ ជួនកាលទល់លាមក ច្រើនស្រេកទឹក ជួនកាលហើមពោះ រួចហើយរាគរូសយ៉ាងខ្លាំង
- ដេកស្ពឹកមួយកន្លែង បណ្ដាលឱ្យសត្វបាត់បង់លទ្ធភាពពលកម្ម និងលទ្ធភាពបង្កើតកូន ។
- ក្នុងកម្រិតធ្ងន់ សត្វឈឺមិនស៊ីចំណី ក្រពះពេញដោយចំណី បន្ទាប់មករាគរូសខ្លាំងក្លា មានក្លិនស្អុយ ។ តែក្នុងរយៈពេលប៉ុន្មានថ្ងៃ សត្វបាក់កម្លាំងរួចងាប់ក្នុងសភាពបាត់បង់ជាតិទឹកពីក្នុងខ្លួន ។
- កូនគោ កូនក្របីអាយុក្រោម ៦ ខែច្រើនកើតជម្ងឺនេះក្នុងកម្រិតធ្ងន់ធ្ងរ ។

**វិធានការការពារ:**

- ចាក់ថ្នាំទម្លាក់ដង្កូវថ្លើមឱ្យបានទៀងទាត់
- សម្លាប់ ឬកម្ចាត់ខ្យង លីនីអា (Limnea) ។
- វាលស្មៅ: អនុវត្តន៍ការឱ្យស៊ីតាមកន្លែងដែលបានកំណត់ ឬ ក៏កាត់ស្មៅហាលទុកឱ្យគោស៊ី ។
- ទ្រុង ក្រោល: ធ្វើរង្វះបង្ហូរទឹកនោម និងទឹកលាងសម្អាតទ្រុងទៅកន្លែងមួយ រួចហើយផ្អាប់លាមកដើម្បីសម្លាប់ដង្កូវ ។

**ការព្យាបាល:** អាចប្រើថ្នាំណាមួយក្នុងចំណោមថ្នាំខាងក្រោម:

- ដូវ៉ីណិច (Dovrenix) ១ សេសេ ក្នុងទម្ងន់ ២៥ គីឡូក្រាម ។ កន្លែងចាក់គឺចាក់សើរស្បែក ។
- ឬ អ៊ីវ៉ូមិច ស៊ុបភើ: ១ សេសេ ក្នុងទម្ងន់ ៥០ គីឡូក្រាម ។ កន្លែងចាក់គឺចាក់សើរស្បែក ។

### ៧-៣-២- ជម្ងឺទ្រីប៉ាណូស៊ូមៈ

**រោគសញ្ញា:**

- ក្ដៅខ្លាំង ៤០-៤១ អង្សាសេ អូសបន្លាយ ១-៣ ថ្ងៃ រួចហើយចុះមកវិញ ។ ២-៦ ថ្ងៃ ក្រោយក្ដៅឡើងវិញ រួចហើយគឺត្រឡប់ចុះត្រឡប់ឡើង ក្ដៅ ត្រជាក់ៗ បើជម្ងឺស្រាលទាល់តែ ១-២ ខែទើបក្ដៅម្ដង ។
- ភ្នាសស្លេងភ្នែក ក្រហមចេញឈាម បន្ទាប់មកស្លេក រួចហើយលឿងមានអាចម៍ភ្នែកដុំៗ ។
- ហើមជើងទាំងបួន ហើមប្រដាប់បន្តពូជ ពិបាកដើរ
- ដេកបត់ក្បាលមកមួយចំហៀង ទឹកនោមពណ៌លឿង
- មានរោគសញ្ញាសរសៃប្រសាទ: ភ្នែកក្រហម លោតផ្លោះវក់វី កម្ទេចទ្រុង/ក្រោល ។ ក្នុងសភាពស្រាលសត្វឈឺញ័រញាក់ ដួលចុះ ភ្នែកក្រឡាប់ ហៀរទឹកមាត់ ២០-៣០ នាទី ក្រោយមកទើបងើបឈរបានវិញ ។
- កំពុងតែភ្ជួររាស់ ស្រាប់តែដួលផ្ងារ ងាប់យ៉ាងរហ័ស

**ការព្យាបាល:** អ៊ីរ៉ូមិច ស៊ុបភើ: ១ សេសេ ក្នុងទម្ងន់ ៥០ គីឡូក្រាម ។ កន្លែងចាក់គឺចាក់សើរស្បែក ។

**៧-៣-៣- ជម្ងឺព្រូនចង្កឹះ០:**

**រោគសញ្ញា:**

កូនក្របីដែលមានព្រូនចង្កឹះ ដំណើរល្ហេតល្ហត ពោះធំ កោងខ្នង កន្ទុយធ្លាក់ រោមបះ ស្នេញធ្មេញក្នុង សភាព ធ្ងន់ធ្ងរមិនស៊ីចំណី ដេក១កន្លែង ដង្ហើមខ្សោយធុំក្លិនស្អុយ ជួនកាលឈឺពោះបំរះននាល ភ្នាសស្លេកស្លាំងដំបូង លាមកវឹងពណ៌ខ្មៅ ប្រែជាលឿងប្រផេះ មានលាយឈាមក្លិនស្អុយរួចហើយប្រែពីលឿងប្រផេះទៅជារាវ កម្តៅឡើង ដល់ ៤០-៤១ អង្សារសេ កូនក្របីបាក់កម្លាំង ងាប់ ។ ជម្ងឺអាចអូសបន្លាយពី ៥-៣០ ថ្ងៃ កូនក្របីច្រើនងាប់ក្នុងថ្ងៃទី ៧-១៦ ក្រោយពេលមានជម្ងឺ ។

**ការព្យាបាល:** អ៊ីរ៉ូមិច ស៊ុបភើ: ១ សេសេ ក្នុងទម្ងន់ ៥០ គីឡូក្រាម ។ កន្លែងចាក់គឺចាក់សើរស្បែក ។